# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤ ស.ស.រ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារសម្រាប់ឆ្លើយបំភ្លឺទៅនឹងមតិជំទាស់ជាមួយនយោបាយដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា

-----------

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសភាពការណ៍ចាំបាច់

### សម្រេច

**ប្រការ១ :** ត្រូវបានបង្កើតក្រុមការងារសម្រាប់ឆ្លើយបំភ្លឺទៅនឹងមតិជំទាស់ជាមួយនយោបាយដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

- ឯកឧត្តម **យឹម ឆាយលី** ប្រធានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រធាន
- ឯកឧត្តម **ត្រាំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន
- ឯកឧត្តម **អ៊ុក ប្រាជ្ញា** រដ្ឋលេខាធិការក្រសួងព័ត៌មាន អនុប្រធាន
- ឯកឧត្តម **ពិត ចំណាន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- ឯកឧត្តម **ចំនួ គុងអ៊ីវ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ សមាជិក
- ឯកឧត្តម **ឃិន គីមស៊ាន** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក
- ឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក
- ឯកឧត្តម **អ៊ី ឆន** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក
- ឯកឧត្តម **ពេជ្រ សោភ័ណ** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

Ans.doc



www.pheakdeylaw.com

- ឯកឧត្តម **សយ ស៊ីផុន** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- ឯកឧត្តម **នុត ណារ៉ាង** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- ឯកឧត្តម **ស្វាយ ស៊ីថា** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- ឯកឧត្តម **សយ សុខា** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- ឯកឧត្តម **ស៊ាន ទិសុទ្ធ** ប្រធានស្តីទី អង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ សមាជិក
- ឯកឧត្តម **តិច សំណាង** អគ្គលេខាធិការ នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ នៃកម្ពុជា សមាជិក
- ឯកឧត្តម **កែវ វិចិត្រ** អគ្គលេខាធិការស្តីទី នៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ លេខាធិការ

**ប្រការ២** : ក្រុមការងារនេះមានភារកិច្ច :

-សិក្សាស្រាវជ្រាវ ត្រៀមឯកសារពាក់ព័ន្ធ និងកសាងអត្ថបទ អំណះអំណាង ឬទឡ្ហីករណ៍នានា ដើម្បីឆ្លើយបំភ្លឺទៅនឹងមជ្ឈដ្ឋានដែលបានលើកឡើងមួយចំនួន ប្រឆាំងនឹងនយោបាយដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ។

-អញ្ជើញតំណាងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធមករាយការណ៍បំភ្លឺតាមការចាំបាច់ ។

-ធ្វើរបាយការណ៍អំពីលទ្ធផល និងលើកវិធានការដោះស្រាយជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីចាត់ការបន្តទៀត ។

**ប្រការ៣** : សមាជិកក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។
ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចប្រការ ៤
-ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com